-សមាជិកទាំងអស់ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ ។

ការរៀបចំការប្រជុំទាំងឡាយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ និងការតាមដានការអនុវត្តន៍ផែនការសេចក្ដីណែនាំទាំងអស់របស់ខ្លួន ត្រូវបានធានាដោយអគ្គលេខាធិការដ្ឋានទទួលបន្ទុកការងារអតីតយុទ្ធជន ។

មាត្រា ៦ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤៥ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មការរៀបចំទិវា
## មហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- យោងតាមការចាំបាច់នៃការអនុវត្តភាពបើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាច់សតវត្សទី ២០

## សំរេច

មាត្រា ១ ._ បង្កើតគណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មួយដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២-ឯកឧត្តម មិន ឃិន រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង ជាអនុប្រធាន
៣-ឯកឧត្តម ម៉ែន យ៉េន រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន
៤-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាអនុប្រធាន
៥-ឯកឧត្តម-នន់ ទិមុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
៦-ឯកឧត្តមអ៊ុង ភីមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៧-ឯកឧត្តម អ៊ី ដាវ៉ាទុន្ធ រដ្ឋលេខាធិការក្រសួងព័ត៌មាន ជាសមាជិក
៨-ឯកឧត្តម ត្រឹ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក
៩-ឯកឧត្តម ចាប់ ញ៉ាលីខុន អភិបាលខេត្តសៀមរាប ជាសមាជិក
១០-ឯកឧត្តម សេខ ឥុន អភិបាលរងរាជធានីភ្នំពេញ ជាសមាជិក
១១-ឯកឧត្តម កែវ សានិល អនុរដ្ឋលេខាធិការអាកាសចរស៊ីវិល ជាសមាជិក
១២-ឯកឧត្តម ស៊ុំ នន់ អគ្គនាយករងអាជ្ញាធរអប្សរា ជាសមាជិក
១៣-ឯកឧត្តម ប៉ាន់ ចន្ថា ប្រធានក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជា ជាសមាជិក
១៤-លោក ទែម គីមហ៊ាន អគ្គនាយករងក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិក
១៥-លោកឧត្តមសេនីយ៍ ស៊ុម សុផល ប្រធាននាយកដ្ឋានអង្គរក្សក្រសួងមហាផ្ទៃ ជាសមាជិក
១៦-លោក ឡេង ឋានិកា ប្រធាននាយកដ្ឋានព័ត៌មានទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ២ .-** ឆ្លងតាមរយៈទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩ -២០០០ គណៈកម្មការនេះមានបេសកកម្មបង្ហាញជូនទស្សនារម្មណ៍ជាតិ និង អន្តរជាតិនូវ :

-អត្តសញ្ញាណជាតិខ្មែរតំណវង្សពីអង្គរ

-វប្បធម៌ អារ្យធម៌ដ៏រុងរោចន៍នាសម័យអង្គរ ផ្សារភ្ជាប់និងគោលនយោបាយរបស់រាជរដ្ឋាភិបាលនាបច្ចុប្បន្នក្នុងជំហរលើកកំពស់ :

ក-ការពង្រឹងសន្តិភាព

ខ-ផ្សះផ្សារជាតិ និងបង្រួបបង្រួមជាតិ

គ-សាមគ្គីធម៌ជាតិ និងអន្តរជាតិ

ឃ-ការស្តារវីរភាព កិត្តិយស និងសីលធម៌រស់នៅថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្មែរ

ង-តាមរូបភាព និងខ្លឹមសារនៃទស្សនីយភាពប្រែក្លាយទិវាមហោស្រពនេះអោយទៅជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិភពលោកមួយសំដៅបំបាត់រាល់ការបង្អាប់បង្អួចកេរ្តិ៍ឈ្មោះខ្មែរពីសំណាក់បរទេសក្នុងរយៈពេលកន្លងមកដោយប្តេជ្ញាទទួលខុសត្រូវវាសនាខ្លួនឯងនៅថ្ងៃអនាគត ។

**មាត្រា ៣ .-** ដើម្បីសំរេចនូវបេសកកម្មខាងលើនេះ គណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មានភារកិច្ច ដូចតទៅ ៖

-បើកអង្គប្រជុំជាញឹកញាប់ដើម្បីពិភាក្សាពិគ្រោះយោបល់ និងបែងចែកភារកិច្ចដែលពាក់ព័ន្ធនឹងជំនាញមុខសញ្ញាជូនសមាជិកទទួលខុសត្រូវរៀងៗខ្លួន
-ធ្វើសារាចរណែនាំស្តីពីការប្រារព្ធទិវាមហោស្រពឆ្នាំ ១៩៩៩-២០០០
-រៀបចំតារាងប្រធានបទ ខ្លឹមសារ រូបភាពបរើអោយទិវាមហោស្រពនេះ
-បង្កើតអនុគណៈកម្មការមួយចំនួនដើម្បីប្រគល់ភារកិច្ចដោយឡែកតាមភាពចាំបាច់
-តាមដានត្រួតពិនិត្យ កែសំរួលជាជំហានៗ នូវរាល់សកម្មភាពរបស់ផ្នែកនីមួយៗ
-បំផុស និងអំពាវនាវគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ប្រជាជន មហាជន សប្បុរសជន ដើម្បីជួយឧបត្ថម្ភគាំទ្រចំពោះទិវាមហោស្រពនេះ
-បំផុសអោយមហាជន ទេសចរជាតិ និង អន្តរជាតិចូលរួមក្នុងទិវាមហោស្រពនេះ អោយបានកុះករ
-ធ្វើវេទយិតកម្មអប់រំដល់ មន្ត្រីរាជការ នគរបាល កងទ័ព សិស្ស និស្សិត ប្រជាពលរដ្ឋគ្រប់ស្រទាប់ និង ព្រះសង្ឃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា អោយជួយជ្រោងខ្ពស់ទិវាមហោស្រពប្រវត្តិសាស្ត្រនេះ
-ផ្សព្វផ្សាយ និងអំពាវនាវចំពោះសិប្បករខ្មែរអោយខិតខំសំរាំងស្នាដៃ ផលិតនូវវត្ថុសិល្បៈពាក់ព័ន្ធនិងវប្បធម៌ អារ្យធម៌អង្គរជាពិសេស ប្រជាពលរដ្ឋ ខេត្តសៀមរាបទាំងមូល ដើម្បីលក់យកកំរៃនៅអំឡុងពេលប្រព្រឹត្តទៅនៃមហោស្រពនោះ
-ត្រៀមលក្ខណៈរៀបចំទីលានមុខប្រាសាទអង្គរវត្ត ដើម្បីសំដែង និងប្រារព្ធពិធី
-រកគ្រប់លទ្ធភាពបើកប្រាសាទមួយចំនួនទៀត ដូចជាទីលានជល់ដំរី និងស្រះស្រង់ ជាដើម សំរាប់ធ្វើនិទស្សន៍អំពីឆ្នាំសន្តិភាព ទេសចរណ៍ ចំពោះមជ្ឈដ្ឋានជាតិ និងអន្តរជាតិ

មាត្រា ៤ ._ កំណត់យកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៩ ជាថ្ងៃពិធីបើកមហោស្រព ( ថ្ងៃចូលបុណ្យ )
-ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៩ ជាទិវាប្រកាស បិទ / បើកសតវត្ស និង ឆ្នាំ សន្តិភាព- ទេសចរណ៍ ដោយ សម្តេចនាយករដ្ឋមន្ត្រី
-និងថ្ងៃទី ០១ ខែមករា ឆ្នាំ២០០០ ជាថ្ងៃបិទមហោស្រព ។

មាត្រា ៥ ._ គណៈកម្មការជាតិរៀបចំទិវាមហោស្រព ឆ្នាំ១៩៩៩-២០០០ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៦ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះជាពិសេស អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សាលាក្រុងភ្នំពេញ គណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

អាជ្ញាធរអប្សរា និងស្ថាប័នពាក់ព័ន្ធព្រមទាំង សាមីជនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤៦ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៨ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរជំពូក និង ផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី